**មាត្រា ៥** : ក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កំណត់សំរេច ។

**មាត្រា ៦** : បទបញ្ញត្តិទាំងឡាយណាដែលមានពីមុន ហើយផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ស្ថាប័នមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

**មាត្រា ៨** : អនុក្រឹត្យនេះ មានអនុភាពគតិយុត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

## អនុក្រឹត្យលេខ ៧៣ អនក្រ-បក
## ស្តីពីការបង្កើតតំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើររបស់រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល .

**សម្រេច**

**មាត្រា ១** : បង្កើតតំបន់ឧស្សាហកម្មមួយនៅក្នុងខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុមាន ឈ្មោះថា « តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ » ។

**មាត្រា ២** : តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ ជាតំបន់អភិវឌ្ឍន៍ឧស្សាហកម្មពិសេសមួយដែលប្រមូលផ្ដុំសកម្មភាពឧស្សាហកម្មទូទៅ ឧស្សាហកម្មនាំចេញ ឧស្សាហកម្មសេរី និង សេវាកម្មដទៃទៀត ដែលបំរើឱ្យកិច្ចការផលិតកម្ម អាជីវកម្ម នៃតំបន់នេះ ។

**មាត្រា ៣** : តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ មាន ÷

- តំបន់ឧស្សាហកម្ម ទូទៅជាមណ្ឌល នៃសកម្មភាពឧស្សាហកម្ម និង សកម្មភាពដទៃទៀតដែលពាក់ព័ន្ធ នឹងការផលិតទំនិញសំរាប់សេចក្ដីត្រូវការក្នុងប្រទេស ឬ និងសំរាប់ការនាំចេញ ។
- តំបន់ឧស្សាហកម្មនាំចេញ ជាមណ្ឌលនៃសកម្មភាពឧស្សាហកម្ម និង សកម្មភាពដទៃទៀតដែលពាក់ព័ន្ធ និងការផលិតទំនិញសំរាប់ការនាំចេញ ចាប់ពី ៨០ % ឡើងទៅ ។

– តំបន់ឧស្សាហកម្ម - សេវាកម្ម គឺជាមណ្ឌលរួចពន្ធ នៃសកម្មភាពផ្គត់ផ្គង់ ស្តុកដាក់តាំង វេចខ្ចប់ផ្តុំផ្សំសំអាត បង្ហើយការ នូវផលិតផល សំភារបរិក្ខារ និងសំភារៈដទៃទៀតដែលមិនមានការហាមឃាត់ ដោយច្បាប់ សំរាប់បំរើឱ្យសកម្មភាពឧស្សាហកម្ម ។

**មាត្រា ៤** : តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុមានទំហំប្រមាណ១.១៥០ ហិកតា មានទីតាំងដូចបានបញ្ជាក់តាមផែនទី ដែលមានភ្ជាប់នឹងអនុក្រឹត្យនេះ និងដែលស្ថិតនៅក្នុងចន្លោះ ។

**ចាប់ពី**

ខ្សែរយៈទទឹង ១០° ៤៣,២ ខ្សែរយៈបណ្តោយ ១០៣° ៣២,៨

និងខ្សែរយៈទទឹង ១០° ៤២,៣ ខ្សែរយៈបណ្តោយ ១០៣° ៣២,៩

**ទៅដល់**

ខ្សែរយៈទទឹង ១០° ៤៤,១ ខ្សែរយៈបណ្តោយ ១០៣° ៣៧,២

និងខ្សែរយៈទទឹង ១០° ៤៣,២ ខ្សែរយៈបណ្តោយ ១០៣° ៣៧,៤

អាងទឹកសាបដែលមានសញ្ញាបញ្ជាក់ក្នុងផែនទី ជាប្រភពទឹកសាបសំរាប់បំពេញសេចក្តីត្រូវការរបស់តំបន់ឧស្សាហកម្ម ស្ទឹងហាវ ក្រុងព្រះសីហនុ ។

**មាត្រា ៥** : ផ្ទៃដីទាំងអស់ដែលនៅក្នុងបរិវេណតំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ ដូចបានកំណត់ក្នុងមាត្រា ៤ ជាកម្មសិទ្ធិរបស់រដ្ឋ ហើយត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាព និងដំណើរការ ត្រូវកំណត់ឡើងដោយអនុក្រឹត្យ ។

**មាត្រា ៦** : ដើម្បីដំណើរការចាត់ចែងតំបន់ឧស្សាហកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានភារកិច្ចរៀបចំធ្វើសំណើបង្កើតអាជ្ញាធរតំបន់ឧស្សាហកម្មជា ដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាពជាតំណា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

••••••

# ផែនទី

## តំបន់ឧស្សាហកម្ម ស្ទឹងហាវ - ក្រុងព្រះសីហនុ

តំបន់ឧស្សាហកម្មទូទៅ ≈ ១១៥០ ហិកតា




កំណត់សំគាល់

(ក) អាងទឹកសាប

- - — ខណ្ឌសីមានៃតំបន់ឧស្សាហកម្មទូទៅ

——— ផ្លូវរថភ្លើង

០ ៥០០ ១០០០ ១៥០០ ម៉

ក្រសួង ស្ថាប័ននានាដែលពាក់ព័ន្ធ ។ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អាជ្ញាធរតំបន់ឧស្សាហកម្មកម្ពុជា នឹងត្រូវកំណត់ឡើងដោយអនុក្រឹត្យ ។

**មាត្រា ៧** : បទបញ្ញត្តិផ្ទុយទាំងឡាយណាដែលមានឋានានុក្រមស្មើ ឬ ទាបជាងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋាន នៃស្ថាប័នពាក់ព័ន្ធ និងអភិបាលក្រុងព្រះសីហនុ មានភារកិច្ចអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះតាមសមត្ថកិច្ចរៀង ៗ ខ្លួន ។

**មាត្រា ៩** : អនុក្រឹត្យនេះចាប់ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

## អនុក្រឹត្យលេខ ៧៤ អនក្រ
## ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ ហិរញ្ញវត្ថុសំរាប់ ការគ្រប់គ្រងឆ្នាំ ១៩៩៥
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា